# មិនជាអ្វីទេ តែវាស្អុយ ?

របប ក្រុង ភ្នំពេញ គេ មិន ឱ្យ សារៈសំខាន់ ដល់ ការដាក់ ទណ្ឌកម្ម របស់ សហរដ្ឋ អាមេរិក ដល់ គន់ គីម និង ទ្រី ភាព ព្រោះ គេ យល់ ឃើញ ថា វា មិន ជា អ្វី ទេ ដល់ របប របស់ គេ។ តែ របប នេះ ភ្លេច គិត ថា វា មិន ជា អ្វី ទេ ដល់ ខ្លួន តែ ខ្លួន ភ័ន្ត ព្រោះ ថា វា មាន មាន ក្លិន ស្អុយ ចេញ ពី ខ្លួន ភាយ ពាស ពេញ នៅ ក្នុង និង ក្រៅ ស្រុក ដែល វា នាំ ឱ្យ នគរខ្មែរ អាម៉ាស់ កេរ្តិ៍។ តាម ធម្មតា របប នេះ រមែង ប្ដឹង ជនណា ទៅ តុលាការ ដែល ហ៊ាន រិះគន់ លើ អ្វី មួយ ដល់ ខ្លួន ថា បរិហារកេរ៍ ហើយ ឱ្យ ចៅក្រម ជា អាយ៉ង របស់ ខ្លួន កាត់ទោស នរៈនោះ ដាក់ ព័ន្ធនាគារ។ ហេតុ អ្វី បាន ជា របប នេះ មិន ប្ដឹង ក្រសួង រតនាគារ អាមេរិកាំង បើ ជឿង ជាក់ច្បាស់ ថា គូកន ខ្លួន ជា ជន ស្អាតស្អំ ? បើ នៅ ប្រទេស មាន នីតិរដ្ឋ រឿង អាស្រូវ លើ ឆាក អន្តរជាតិ បែប នេះ ច្បាស់ ជា រដ្ឋសភា គេ បង្កើត គណកម្មការ ស៊ើបអង្កេត ដើម្បី ស្វែង រក ការពិត។ តែ ការពិត នៅ ស្រុក ខ្មែរ វា នៅ លើ ត្រឹមតែ បបូរមាត់ ហ៊ុន សែន តែ ប៉ុណ្ណោះ។ នរៈនេះ នៅ តែ មាន ជំនឿ ថា របប របស់ ខ្លួន នៅ តែ អាច បន្ត ធ្វើ សកម្មភាព ប្រឆាំង និង សិទ្ធិ មនុស្ស និង លទ្ធិ ប្រជាធិបតេយ្យ ដោយ គ្រាន់ តែ មិន រវល់ នឹង ទណ្ឌកម្ម អន្តរជាតិ។ ពោល បែប នេះ វា ងាយស្រួល ពេក ព្រោះ ពេចន៍ នេះ វា គ្មាន តម្លៃ ទេ នៅ ក្នុង ច្បាប់ អន្តរជាតិ និង ធម្មជាតិ។ ការដាក់ ទណ្ឌកម្ម វា តែងតែ មាន គោលដៅ វា ច្បាស់លាស់ ណាស់៕

ឧប សៅ សន្ធា គំនិត ១២ ធ្នូ ២០១៩